**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៤៩/០០៣/២០០២

ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២

**សេចក្តីសំរេច**

លេខ : ០៤៦/០០១/២០០២ កបធ.ធ

ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០២

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស / រកម / ០៤៩៨ / ០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ជស / រកម / ១៩៩៧ / ០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពី គណបក្សនយោបាយ

-បានឃើញពាក្យបណ្តឹងលេខ ៥៩៧ រស ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា កែប្រែដោយពាក្យបណ្តឹង លេខ ៦១៦ រស ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ( ដោយខុសឆ្នាំពី ២០០១ មក ២០០២ វិញ) សុំអោយក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៣៨ ជំពូកទី ៩ នៃច្បាប់ស្តីពី គណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស តាមសំណូមពររបស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ( ខុមហ្វ្រែល COMFREL ) តាមពាក្យបណ្តឹងលេខ ៣២៧ / ០២ គ.ប.ស.យ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០២ និងពាក្យបណ្តឹងកែប្រែបានទទួលនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៨ នៃព្រះរាជក្រមលេខ ជស / រកម / ០៤៩៨ / ០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា កែប្រែដោយពាក្យបណ្តឹងរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ខាងលើ អាចទទួលយកមកពិចារណាបាន ។

-យល់ឃើញថា តាមមាត្រា ១២៨ ថ្មី វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃរដ្ឋធម្មនុញ្ញ : " *អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។*

*អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់* " ។

-យល់ឃើញថា :

'មាត្រា ១២៩ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ចែងថា : " *មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី* " ។

'មាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " *គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ* " ។

'មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " *មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា* " ។

-យល់ឃើញថា ការពិន័យដែលអាចធ្វើទៅបាន ក្រៅពីតុលាការ មានតែការពិន័យដែលមានលក្ខណៈជា *ពិន័យអន្តរការណ៍*

-យល់ឃើញថា *ការពិន័យអន្តរការណ៍* អាចធ្វើទៅបាន លុះត្រាតែមាន *ចែងច្បាស់ក្នុងច្បាប់* ព្រមទាំងចែងច្បាស់ពី *អាជ្ញាធររដ្ឋបាលដែលត្រូវអនុវត្ត* ឬច្បាប់បានអនុញ្ញាតអោយចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដូចជា *អនុក្រឹត្យ ប្រកាស* ។ល។ ក្រៅពីករណីនេះ អាជ្ញាធររដ្ឋបាលសាធារណៈពាក់ព័ន្ធមានភារកិច្ចត្រឹមកសាងសំណុំរឿងបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ។

-យល់ឃើញថា បទបញ្ញត្តិក្នុងមាត្រា ៣៨ នេះមិនមានចែងអំពីសមត្ថកិច្ចណាមួយច្បាស់ ឬក៏អនុញ្ញាតឱ្យចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដែរ ។ ដូច្នេះក្រសួងពាក់ព័ន្ធមិនមានសមត្ថកិច្ចលើបទល្មើសនេះទេ ។

-យល់ឃើញថា ការផ្តន្ទាទោសផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្នដែលមានចែងក្នុងមាត្រា ៣៨ ក៏ជាសមត្ថកិច្ចរបស់តុលាការដែរ ។

**សំរេច**

មាត្រា ១ : យោងតាមមូលបទខាងលើ មានតែតុលាការទេដែលមានសមត្ថកិច្ចផ្តន្ទាទោសករណីទាក់ទងនឹងមាត្រា ៣៨ នៃច្បាប់ស្តីពី គណបក្សនយោបាយ ។

មាត្រា ២ : សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអនុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

ជ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

អនុប្រធាន

ប៊ិន ឈិន